**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខៈ..០៣៣/.២០.ស.ជណ

# សេចក្តីជូនដំណឹង

រដ្ឋបាលរាជធានីភ្នំពេញ សូមជម្រាបជូនដំណឹងដល់សាធារណជន ពិសេសបងប្អូនប្រជាពលរដ្ឋទាំងអស់ដែលទើបអញ្ជើញត្រលប់មកពីធ្វើការនៅព្រះរាជាណាចក្រថៃ និងពីបណ្តាប្រទេសមួយចំនួនទៀត ឱ្យបានជ្រាបថា មេរោគកូវីដ ១៩ (Covid-19) បាន និងកំពុងរាតត្បាតនៅទូទាំងពិភពលោក ដោយឡែកនៅព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាលបានរកឃើញអ្នកមានផ្ទុកមេរោគកូវីដ ១៩ (Covid-19) ចំនួន ៨៦ ករណី គិតត្រឹមថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ ហើយមេរោគនេះកំពុងតែបន្តរីករាលដាល ជាបន្តបន្ទាប់។

ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាល និងការចម្លងមេរោគកូវីដ ១៩ (COVID-19) នៅក្នុងរាជធានីភ្នំពេញ ក៏ដូចក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋបាលរាជធានីភ្នំពេញស្នើបងប្អូនប្រជាពលរដ្ឋទាំងអស់ដែលទើបអញ្ជើញត្រលប់មកពីធ្វើការនៅព្រះរាជាណាចក្រថៃ និងពីបណ្តាប្រទេសមួយចំនួនទៀត ត្រូវអនុវត្តតាមការណែនាំដូចខាងក្រោម៖

១. ត្រូវជូនដំណឹងទៅរដ្ឋបាលខណ្ឌទាំង១៤ ដូចមានតារាងលេខទូរស័ព្ទសម្រាប់ទំនាក់ទំនង ដែលជាឯកសារឧបសម្ព័ន្ធ។

២. ត្រូវដាក់ខ្លួនឱ្យនៅដាច់ដោយឡែក រយៈពេល១៤ថ្ងៃ ដោយអនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល។ ក្នុងករណីដែលបងប្អូនមានការលំបាកក្នុងការអនុវត្តសេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ត្រូវរាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន ដើម្បីមានមូលដ្ឋានដោះស្រាយបញ្ហាជូន។

៣. ក្នុងករណីដែលបងប្អូនមានអាការមួយចំនួន ដូចជាក្អក ឡើងកម្តៅ ៣៨ ដឺក្រេ ពិបាកដកដង្ហើម ដែលសង្ស័យថាអាចមានផ្ទុកមេរោគកូវីដ១៩(COVID-19) សូមបងប្អូនទំនាក់ទំនងតាមរយៈលេខទូរស័ព្ទដូចមានឯកសារឧបសម្ព័ន្ធភ្ជាប់មកជាមួយ ឬអាចទំនាក់ទំនងដោយផ្ទាល់ទៅអាជ្ញាធរភូមិ ប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ និងរដ្ឋបាលសង្កាត់ និងមន្ទីរពេទ្យរដ្ឋ ដែលនៅជិតទីកន្លែងរស់នៅរបស់បងប្អូន ជាបន្ទាន់។

៤. អាជ្ញាធរភូមិ ប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់ និងរដ្ឋបាលសង្កាត់ត្រូវរាយការណ៍បន្ទាន់ក្នុងករណី ដែលទទួលបានព័ត៌មានថាមានបងប្អូនប្រជាពលរដ្ឋដែលទើបអញ្ជើញត្រលប់មកពីធ្វើការនៅព្រះរាជាណាចក្រថៃ និងពីបណ្តាប្រទេសមួយចំនួនទៀត ទៅរដ្ឋបាលខណ្ឌ ដើម្បីអនុវត្តវិធានការបង្ការ និងទប់ស្កាត់ការរាលដាលនៃមេរោគកូវីដ (COVID-19) និងត្រូវចុះអប់រំណែនាំដល់បងប្អូនប្រជាពលរដ្ឋទាំងអស់នោះ អំពីការដាក់ខ្លួនឱ្យនៅដាច់ដោយឡែក រយៈពេល ១៤ថ្ងៃ។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦៦៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

# លេខទូរស័ព្ទរបស់រដ្ឋបាលខណ្ឌទាំង១៤សម្រាប់ទំនាក់ទំនង

| ល.រ | រដ្ឋបាលខណ្ឌ | តួនាទី | ឈ្មោះអ្នកទំនាក់ទំនង | ទូរស័ព្ទទំនាក់ទំនង |
|---|---|---|---|---|
| ១ | ដូនពេញ | អភិបាលខណ្ឌ | លោក សុខ ពេញវុធ | ០១២ ២៥៦ ៨៦៨ |
| | | អភិបាលរងខណ្ឌ | លោក ចាន់ គន្ធេត | ០១២ ៩១៣ ៦៣១ |
| | | នាយករដ្ឋបាលខណ្ឌ | លោក ចាប ឌីណា | ០១៧ ៨៨៨ ៨៨៨ |
| | | ប្រធានការិ.សង្គមកិច្ចនិងសុខុមា-លភាពសង្គម | លោក គង់ នី | ០១១ ២៨២ ៨២៣ |
| ២ | ៧មករា | អភិបាលរងខណ្ឌ | លោកស្រី ទាវ ឆវៃនីព៉ា | ០១២ ៨៣២ ២០៧ |
| | | នាយករដ្ឋបាលស្ដីទី | លោក ម៉ប់ សារ៉េត | ០១២ ៩០៧ ៩២៦ |
| | | នាយករងរដ្ឋបាល | លោក ឈួន ឆាយារិទ្ធ | ០១៧ ៨៨៨ ៨២៨ |
| ៣ | ដង្កោ | អភិបាលខណ្ឌ | លោកស្រី គឹម ញឹប | ០៨៩ ៩៧៨ ៨៨៨ |
| | | អភិបាលរងខណ្ឌ | លោក ជ គឹមសិ | ០១២ ៧១៩ ៥៩៥ |
| | | អភិបាលរងខណ្ឌ | លោក ម៉ុក ពុទ្ធា | ០១២ ២២៧ ៩១៩ |
| ៤ | មានជ័យ | អភិបាលរងខណ្ឌ | លោក ឌី រ័ត្នខេមរុណ | ០១៧ ៨១៥ ៧៥៧ |
| | | នាយករដ្ឋបាលខណ្ឌ | លោក ប្រាំង សុផល | ០១៧ ៩៦៣ ៣៣៦ |
| | | ប្រធានការិយាល័យ សង្គមកិច្ចនិងសុខុមាលភាពសង្គម | លោកស្រី វស់ ថូ | ០១១ ៦១២ ០២៦ |
| ៥ | ពោធិ៍សែនជ័យ | អភិបាលរងខណ្ឌ | លោកអ៊ុត ជំនិត | ០១២ ៩១៨ ១៨២ |
| | | នាយករដ្ឋបាលខណ្ឌ | លោក យ៉ិន គា | ០១២ ៨៤៣ ៥៥១ |
| | | ប្រធានការិយាល័យរដ្ឋបាល | លោក ព្រុំ ភក្រ្តា | ០១១ ៧២២ ១៨៥ |
| | | អនុប្រធានការិយាល័យរដ្ឋបាល | លោកស្រីគា គឹមយ៉ | ០៩២ ៨៥៣ ៩៤៨ |
| ៦ | សែនសុខ | អភិបាលខណ្ឌ | លោក ម៉ូវ ម៉ានិត | ០១២ ៨២២ ៨៨៧ |
| | | អភិបាលរងខណ្ឌ | លោក សាំង សុភៈវិចិត្រ | ០១១ ៨៩៨ ៩៨៩ |
| | | នាយករងរដ្ឋបាល | លោកស្រី សុង សុភា | ០១២ ៧៣៧ ៣១៦ |
| | | ប្រធានការិ.សង្គមកិច្ច និងសុខុមា-លភាពសង្គម | លោក មាន សុផានី | ០១២ ២៨៩ ៦៦៨ |
| ៧ | ចំការមន | អភិបាលរងខណ្ឌ | លោក អាំង សិរីពិសិដ្ឋ | ០១១ ៩៨៨ ៨៨៧ |
| | | អភិបាលរងខណ្ឌ | លោក កែវ សំណាង | ០១៧ ៧៦៣ ៣៣៣ |
| | | នាយករដ្ឋបាល | លោក ស៊ុន សិទ្ធី | ០១២ ៨៥៦ ២២២ |
| ៨ | បឹងកេងកង | អភិបាលរងខណ្ឌ | លោក គីម ណៃរិៈខេមរា | ០១៧ ៨៥២ ៨៨៥ |
| | | នាយករដ្ឋបាល | លោក យុត ឡុងឌី | ០៧៨ ៦៦៦ ៦២៧ |
| | | ប្រធានការិយាល័យដោះស្រាយវិវាទនៅមូលដ្ឋាន | លោក ថេង ចន្ទ័ពិសិដ្ឋ | ០១២ ៥៦៥ ៥៩៥ |
| ៩ | ឫស្សីកែវ | អភិបាលរងខណ្ឌ | លោកស្រី សួស សូលីដា | ០១២ ៦៧៥ ៦៦៦ |
| | | នាយករដ្ឋបាល | លោក សន សោភ័ណ្ឌ | ០១៧ ៦០៦ ៥១៨ |
| | | នាយករងរដ្ឋបាល | លោក ស៊ូ សាភ៉ាត់ | ០១២ ៦៨៣ ៣៣៨ |

| | | | | |
|---|---|---|---|---|
| ១០ | ព្រែកព្នៅ | អភិបាលរងខណ្ឌ | លោក ជា ខេមា | ០៧៧ ៩១៧ ៧៧៧ |
| | | នាយករដ្ឋបាល | លោក ស៊ឹម សុផង់ | ០១២ ៧២៣ ៣៦៦ |
| | | នាយករងរដ្ឋបាល | លោកហែម ឫទ្ធី | ០១២ ៦២ ៩៩ ៨៣ |
| ១១ | កំបូល | អភិបាលខណ្ឌ | លោក ឃឹម ស៊ិនសូដា | ០១២ ៥១៥ ១១៨ |
| | | អភិបាលរងខណ្ឌ | លោកស្រី ទេព កញ្ញា | ០១២ ៥៦៣ ៨៨២ |
| | | នាយករដ្ឋបាល | លោក លឹម ចាន់ដារុធ | ០៨៩ ៥៩៨ ៥៩៨ |
| | | នាយករងរដ្ឋបាល | លោក ទ្រី ណារ៉េត | ០១១ ៨០១ ៦១៧ |
| ១២ | ជ្រោយចង្វារ | អភិបាលរងខណ្ឌ | លោក ហ៊ុយ សារុណ | ០១២ ២៩៩ ៧៧៥ |
| | | នាយករដ្ឋបាល | លោក សែម ដារិទ្ធ | ០១២ ៦៩៨ ៥៦៥ |
| | | ប្រធានការិយាល័យរដ្ឋបាល និង បុគ្គលិក | លោក កេត រតនា | ០៩៧ ៣៧០ ២២២ |
| ១៣ | ច្បារអំពៅ | អភិបាលខណ្ឌ | លោក ចេង មុនីរ៉ា | ០១២ ៨៧១ ៨៨២ |
| | | នាយករដ្ឋបាល | លោក ញាណ ចន្ទសោភា | ០១២ ៨៨៣ ៦៨៣ |
| | | នាយករងរដ្ឋបាល | លោក ស្រេង គឹមស្រ៊ន | ០១២ ៩៥៦ ៥៣៧ |
| ១៤ | ទួលគោក | អភិបាលរងខណ្ឌ | លោក កែវ សុភា | ០១៧ ៣៨៨ ៩៨៨ |
| | | អនុប្រធានការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ | លោក ហៃ ហុង | ០១២ ៩៩៣ ៣១៩ |
| | | អនុប្រធានការិយាល័យប្រធានការិ .សង្គមកិច្ច និងសុខុមាលភាពសង្គម | លោក ហ៊ាន បញ្ញា | ០១២ ៦៥៨ ៥៥៦ |

រដ្ឋបាលរាជធានីភ្នំពេញមានក្តីសង្ឃឹមយ៉ាងមុតមាំថា  បងប្អូនប្រជាពលរដ្ឋទាំងអស់ដែលទើបអញ្ជើញត្រលប់មកពីធ្វើការនៅព្រះរាជាណាចក្រថៃ និងពីបណ្តាប្រទេសមួយចំនួនទៀត ត្រូវចូលរួមទប់ស្កាត់ការរីកពលដាលមេរោគកូវីដ ១៩ (Covid-19) នេះ ដើម្បីសេចក្តីសុខក្រុមគ្រួសារជាទីស្រឡាញ់ សាច់ញាតិក៏ដូចសង្គមជាតិយើងផងដែរ។

ទទួលបានសេចក្តីជូនដំណឹងនេះ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌទាំង១៤ មន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីជូនដំណឹងនេះ ឱ្យទទួលបានលទ្ធផលល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ចន្ទ ១៤ រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០២០

**អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ**

ឃួង ស្រេង

***កន្លែងទទួល៖***
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសុខាភិបាល
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  *-ដើម្បីគោរពជូនជ្រាប-*
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- សាលាខណ្ឌទាំង១៤
- មន្ទីរសុខាភិបាលរាជធានីភ្នំពេញ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ
- មន្ទីរព័ត៌មានរាជធានីភ្នំពេញ
  *-ដើម្បីអនុវត្ត-*
- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ *-ដើម្បីជួយផ្សព្វផ្សាយ-*
- ឯកសារ-កាលប្បវត្តិ

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh